# អនុក្រឹត្យ លេខ ៤១ អនក្រ.បក

## ស្តីពីការអនុវត្តន៍ព្រះរាជក្រម លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០១ នស/ ចុះថ្ងៃទី២៨ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស./រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស./រកម/១២០៥/០៧ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៩៥ ស្តីពីច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៦
- បានឃើញព្រះរាជក្រមលេខ នស./រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស./រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានការយល់ព្រមពីគណៈរដ្ឋមន្ត្រី នាសម័យប្រជុំ ថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៧
- តាមសំណើរបស់ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សំរេច**

### ជំពូក ១

### បទបញ្ញត្តិទូទៅ

**មាត្រា ១ .-**

**១.១** ដោយអនុលោមតាមនយោបាយរៀបចំរចនាសម្ព័ន្ធ ផ្នែកសហគ្រាសសាធារណៈ ជាថ្មីឡើងវិញ របស់ រាជរដ្ឋាភិបាល ចាប់ពីថ្ងៃចូល ជាធរមាននៃ អនុក្រឹត្យនេះតទៅ ក្នុងរយៈពេលមួយ

ឆ្នាំ គ្រប់អង្គភាពឧស្សាហកម្ម និងពាណិជ្ជកម្មរបស់រដ្ឋដែលពុំទាន់មាននីតិបុគ្គលភាពគតិយុ
អង្គភាពសាធារណៈ និងសហគ្រាសដែលជាកម្មសិទ្ធិរបស់រដ្ឋ ត្រូវក្លាយជាកម្មវត្ថុ
វិធានណា មួយក្នុង ចំណោមវិធានដូចខាងក្រោមនេះ :

១-ធ្វើការជំរះបញ្ជី

២-ចាត់ថ្នាក់ចូលក្នុងប្រភេទគតិយុត្តណាមួយនៃបណ្ដាប្រភេទគតិយុត្ត ដែលមានចែងក្នុងច្បាប់
គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច (គ,ស,ស) ក្រុមហ៊ុនរដ្ឋ (ក្រ,
ក្រុមហ៊ុន ចំរុះ(ក្រ,ច) ដែលភាគកម្មសាធារណៈមានចំនួនភាគច្រើន ឬភាគតិចនៃដើ
ទុនសរុប ។ ក្រោយរយៈពេលមួយឆ្នាំ បណ្ដាអង្គភាពឧស្សាហកម្ម និងពាណិជ្ជកម្មរបស់
ដែលពុំទាន់ មាននីតិបុគ្គលភាពគតិយុត្ត និងគ្រប់សហគ្រាស ដែលពុំស្ថិតជាកម្មវត្ថុ នៃ
ចាត់ថ្នាក់ខាងលើទេ នោះត្រូវ ចាត់ស្វ័យប្រវត្ត ស្ថិតក្នុងស្ថានភាពធ្វើការជំរះបញ្ជី ។

១.២ ផុតរយៈពេលមួយឆ្នាំ បើក្រសួង ឬអាជ្ញាធរអាណាព្យាបាលបច្ចេកទេស និងបានសំណូម
បញ្ចូលអង្គភាពក្រោមការគ្រប់គ្រងរបស់ខ្លួនចូលក្នុងវិធានណាមួយ ដូចចែងក្នុងវាក្យខ័
១.១ ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំសំណើផ្ទាល់ទៅរាជរដ្ឋាភិបាល ។

១.៣ ចំពោះអង្គភាពឧស្សាហកម្ម និងពាណិជ្ជកម្មរបស់រដ្ឋ ដែលពុំមាននីតិបុគ្គលភាពគតិយុ
របស់រដ្ឋ -អង្គភាពសាធារណៈ និងសហគ្រាសដែលជាភាគកម្មជាកម្មសិទ្ធិរបស់រដ្ឋ ហើ
ដែលស្ថិតក្នុងសេចក្ដីសំរេចរបស់គណៈរដ្ឋមន្ត្រីសំរាប់ធ្វើឯកជនភាវូបនីយកម្មនោះក្នុងករណី
ចាំបាច់អាចរក្សាទុកនូវលក្ខន្តិកៈគតិយុត្តបច្ចុប្បន្នរបស់ខ្លួនសិនមុនដល់ពេលរៀបចំដំណើរការ
ឯកជនភាវូបនីយកម្ម

## ប្រការ ២.-

ក្នុងនាមជានីតិបុគ្គលស្វយ័ត សហគ្រាសសាធារណៈទាំងឡាយ ត្រូវមានលក្ខណៈសម្
ដូចតទៅ :

១- មាននាមករណ៍ និងទីស្នាក់ការរបស់ក្រុមហ៊ុន

២- មានកម្មវត្ថុច្បាស់លាស់របស់ក្រុមហ៊ុន

៣-មានក្រុមប្រឹក្សាភិបាល និងការគ្រប់គ្រងដោយឡែក

៤- មានថវិកាផ្ទាល់

៥- មានទ្រព្យសម្បត្តិសំរាប់ធ្វើសកម្មភាព ដូចមានគ្រោងទុកក្នុងកម្មវត្ថុរបស់ក្រុមហ៊ុន

៦- មានសមត្ថភាពចុះកិច្ចសន្យា និងប្ដឹង ឬការពារនៅតុលាការ

២២.៤.វិធានការទាំងឡាយដែលមានចែងខាងលើនេះ មិនមែនជាឧបសគ្គរាំងមិនឱ្យអនុវត្តបទបញ្ញត្តិនៃច្បាប់ និងបទបញ្ជាស្តីពីឯកជនភាវូបនីយកម្មសហគ្រាស និងទ្រព្យសកម្មរបស់រដ្ឋទេ ។

## ជំពូក៣

## បទបញ្ញត្តិដោយឡែកសំរាប់ប្រភេទនានានៃសហគ្រាសសាធារណៈ

### ផ្នែកទី១ : គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច

**មាត្រា ២៣.** ការរៀបចំ និងការប្រព្រឹត្តិទៅ បុព្វសិទ្ធ និងអំណាចរបស់ គ.ស.ស ត្រូវកំណត់ដោយៈ

-ព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ និងបទបញ្ញត្តិទាំងឡាយស្តីពីការអនុវត្តន៍ព្រះរាជក្រមនេះ ។

-អនុក្រឹត្យស្តីពីការបង្កើតសហគ្រាសសាធារណៈ និងលក្ខន្តិកៈដែលជាឧបសម្ព័ន្ធព និងបទបញ្ញត្តិនៃច្បាប់ និងបទបញ្ជា អនុវត្តសំរាប់ក្រុមហ៊ុនពាណិជ្ជកម្ម ដែលមិនផ្ទុយនឹងអត្ថបទដែល ចែងខាងលើ ជាពិសេសស្តីពីទំនាក់ទំនង គ.ស.ស ជាមួយតតិយជន ។

**មាត្រា ២៤.** លក្ខន្តិកៈនៃ គ.ស.ស ត្រូវបានរៀបចំឡើងដោយក្រសួងអាណាព្យាបាលបច្ចេកទេស សហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយត្រូវភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងអនុក្រឹត្យស្តីពី ការបង្កើតសហគ្រាសនេះ ។

**មាត្រា ២៥.** គ.ស.ស អាចចាត់ទុកត្រូវបានបង្កើតចាប់ពីថ្ងៃចុះហត្ថលេខាលើអនុក្រឹត្យ ។ ដំណើរការអនុវត្តន៍នឹងអាចប្រព្រឹត្តទៅបាន បន្ទាប់ពីការតែងតាំងសមាជិកប្រធាន នៃក្រុមប្រឹក្សាភិបាល និង អគ្គនាយក ។

**មាត្រា ២៦.** មូលធនរបស់ គ.ស.ស អាចចែកចេញជាភាគទុនជារូបិយវត្ថុ និងភាគទុនជាចលនៈ និងអចលនៈទ្រព្យ ។ ភាគទុនជាចលនៈនិងអចលនៈទ្រព្យត្រូវវាយតំលៃដោយគណៈកម្មការវាយតំលៃមួយ ដែលរួមមានសមាជិកចាត់តាំងដោយរដ្ឋមន្ត្រី ក្រសួងអាណាព្យាបាលបច្ចេកទេស និងរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា ២៧.** ប្រតិបត្តិការហិរញ្ញវត្ថុទាំងឡាយរបស់រដ្ឋក្នុងឋានៈជាម្ចាស់ភាគហ៊ុននិង គ.ស.សត្រូវអនុលោមតាមបញ្ញត្តិចែងដោយព្រះរាជក្រមលេខ ១នស/៩៣ ចុះថ្ងៃទី២៨ ធ្នូ ឆ្នាំ១៩៩៣ ស្តីពី ប្រព័ន្ធច្បាប់ហិរញ្ញវត្ថុ និងលិខិតបទដ្ឋានបន្តបន្ទាប់ក្រោយៗទៀត ។ កិច្ចការនេះតំរូវ :

១- ភាគទុនជាមូលធនចាប់ពីពេលបង្កើត ឬក្រោយការបង្កើត គ.ស.ស ត្រូវបានគ្រោង អនុញ្ញាតដោយច្បាប់ហិរញ្ញវត្ថុដោយចាត់ទុកជាចំណាយលើការវិនិយោគរបស់រដ្ឋក្នុងកិច្ច តិបត្តិការហិរញ្ញវត្ថុ ។

២- ចំណូលដែលរដ្ឋបានមកពី គ.ស.ស គឺជាប្រភពចំណូលថវិកា :

- (I) ទុកជាចំណូលមូលធនក្នុងប្រទេស ក្នុងករណីលក់ គ.ស.ស

- (II) ឬទុកជាចំណូលនៃទ្រព្យសម្បត្តិរដ្ឋ ក្នុងករណីជាប្រាក់ចំណេញតាមភាគហ៊ុន ។

## ជំពូកទី២ : ក្រុមហ៊ុនរដ្ឋ

**មាត្រា ២៨.-** ការរៀបចំ និងការប្រព្រឹត្តទៅ បុព្វសិទ្ធ និងអំណាចរបស់ ក្រ.រ ត្រូវកំណត់ដោយ:

-ព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិនា ឆ្នាំ១៩៩៦ និងបញ្ញ ទាំងឡាយស្តីពីការអនុវត្តនីព្រះរាជក្រមនេះ ។

-អនុក្រឹត្យស្តីពីការបង្កើតសហគ្រាសសាធារណៈ និងលក្ខន្តិកៈដែលជាឧបសម្ព័ន្ធ៣ និង បញ្ញត្តិនៃច្បាប់និងបទបញ្ញា អនុវត្តសំរាប់ក្រុមហ៊ុនពាណិជ្ជកម្ម ដែលមិនផ្ទុយនឹងអត្ថ ដែលចែងខាងលើ ជាពិសេសស្តីពីទំនាក់ទំនង គ.ស.ស ជាមួយតតិយជន ។

**មាត្រា ២៩.-** លក្ខន្តិកៈរបស់ ក្រ.រ ត្រូវរៀបចំឡើងដោយ ក្រសួងអាណាព្យាបាលបច្ចេកទេសសហការ ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៣០.-**

៣០.១- ទំរង់នៃការបង្កើត ក្រ.រ ត្រូវប្រព្រឹត្តដោយអនុលោមទៅតាមវិធាននៃនីតិក្រុមហ៊ុ ពាណិជ្ជកម្មដោយអាណត្តិអគ្គាហកៈម្នាក់ ដែលជ្រើសរើសដោយរដ្ឋមន្ត្រីក្រសួង អាណាព្យ បាលបច្ចេក ទេសហើយដែលជាអ្នក :

- ដាក់លក្ខន្តិកៈរបស់ក្រ.រ ជូនរដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្ចេកទេស និងរដ្ឋមន្ត្រីក្រសួ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះហត្ថលេខារួម

- ចុះឈ្មោះក្រុមហ៊ុនក្នុងបញ្ជីពាណិជ្ជកម្ម និងក្រុមហ៊ុនជារួមគឺបំពេញបែបបទចាំបាច់ផ្សេង តាមនីតិក្រុមហ៊ុនពាណិជ្ជកម្ម ។

៣០.២- ក្រ.រអាចមាននីតិបុគ្គលចាប់ពីថ្ងៃចុះឈ្មោះក្រុមហ៊ុនក្នុងបញ្ជីពាណិជ្ជកម្ម ។ ចន្លោះថ្ងៃ ចេញអនុក្រឹត្យបង្កើត និងថ្ងៃចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុនមិនអាចសំរេចកិច្ចកា អ្វីមួយបានទេ លើកលែងតែកិច្ចការដែលសំរេចដោយអាណត្តិគាហកៈរបស់រដ្ឋមន្ត្រីក្រសួ អាណាព្យាបាល បច្ចេកទេស ។

ចាត់ឱ្យធ្វើជាលេខាធិការនៃអង្គប្រជុំ ។ កំណត់ហេតុនេះ នឹងត្រូវបញ្ជូនទៅសមាជិកក្រុមប្រឹក្សាភិបាល មន្ត្រីត្រួតពិនិត្យរដ្ឋ រដ្ឋមន្ត្រីអាណាព្យាបាលបច្ចេកទេស និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងអំឡុងពេល១០ថ្ងៃយ៉ាងយូរបន្ទាប់ពីការប្រជុំ ។ ខ្លឹមសារកំណត់ហេតុត្រូវឆ្លុះបញ្ចាំងឱ្យបាន ត្រឹមត្រូវនៃសេចក្ដីនៃការជជែកពិភាក្សា ។ ក្នុងករណីមានយោបល់ជំទាស់របស់សមាជិកក្រុមប្រឹក្សា ភិបាលសំរាប់ការប្រជុំលើកក្រោយត្រូវកត់ត្រានូវយោបល់នោះក្នុងកំណត់ហេតុនេះ ។

**ក្រ: ៩~**

៩.១. សមាសភាពនៃក្រុមប្រឹក្សាភិបាលនៃ គ.ស.ស និង គ្រ.រ អាចរៀបចំតាមរូបមន្តមួយក្នុងចំណោម រូបមន្តពីរដូចតទៅ :

១- ត្រូវមានតែតំណាងរបស់រដ្ឋដែលជាម្ចាស់កម្មសិទ្ធិ ឬជាម្ចាស់ភាគហ៊ុន

២- ត្រូវបែងចែកសមាជិកក្រុមប្រឹក្សាភិបាលជាពីរប្រភេទ : (I) តំណាងរបស់រដ្ឋដែលជាម្ចាស់កម្មសិទ្ធិ ឬម្ចាស់ភាគហ៊ុន (II) តំណាងរបស់ធុរៈជន ពាណិជ្ជករ និង ឬអ្នកប្រើប្រាស់ ។ ក្នុងករណីនេះ តំណាងរបស់រដ្ឋត្រូវឱ្យមានចំនួនភាគច្រើននៅក្នុងក្រុមប្រឹក្សាភិបាល ។ តំណាងរបស់ធុរៈជន ពាណិជ្ជករ ឬអ្នកប្រើប្រាស់ ត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់អង្គការដែល ជាតំណាងរបស់ខ្លួន (សភាពាណិជ្ជកម្ម សមាគមមុខរបរ សមាគមអ្នកប្រើប្រាស់ ។ល។)

៩.២. ម្ចាស់ភាគហ៊ុនសាធារណៈ ជានិច្ចត្រូវមានចំនួនភាគច្រើននៃអសនៈរបស់ក្រុមប្រឹក្សាភិបាលក្នុង **គ្រ.ច** ដែលមានភាគកម្មសាធារណៈចំនួនភាគច្រើន ។

**ក្រ:១០~** អ្នកតំណាងរបស់និយោជិត នឹងត្រូវបានជ្រើសតាំងជាសមាជិកស្វ័យប្រវត្តិនៃក្រុមប្រឹក្សាភិបាល ។ អនុក្រឹត្យស្ដីពីការបង្កើត **គ.ស.ស** ឬ **គ្រ.រ** និង **គ្រ.ច** ដែលមានភាគកម្មសាធារណៈចំនួនភាគច្រើនអាចគ្រោងនូវ សមាជិកស្វ័យប្រវត្តផ្សេងទៀតក្នុងក្រុមប្រឹក្សាភិបាល ។ សមាជិកស្វ័យប្រវត្តិអាចចូលបំពេញការងារក្នុងក្រុមប្រឹក្សាភិបាល ចាប់ពីថ្ងៃដែលខ្លួនត្រូវបានជ្រើសតាំង ឬត្រូវបានតែងតាំងក្នុងមុខងារ ដែលតម្រូវឱ្យចូលរួមក្នុងក្រុមប្រឹក្សាភិបាល ដោយ ពុំចាំបាច់មានការតែងតាំងដោយអនុក្រឹត្យឡើយ ។

ការចប់អាណត្តិនៃការជ្រើសតាំងឬការបាត់បង់មុខងាររបស់សមាជិកគតិយុត្តិនឹងត្រូវបញ្ចប់ការចូលរួមរបស់អ្នកទាំងនោះក្នុងក្រុមប្រឹក្សាភិបាលតាមផ្លូវច្បាប់ជាស្វ័យប្រវត្តិ ។

**មាត្រា១១.**

**១១.១**-សមាជិកក្រុមប្រឹក្សាភិបាល ដែលជាតំណាងនិយោជិត ត្រូវជ្រើសតាំងក្នុងរយៈពេល ៣
យ៉ាងយូរតាមការកំនត់របស់ក្រុមប្រឹក្សាភិបាល ។ អាណត្តិនេះអាចបន្តទៀតបាន ។
សមាជិកស្វ័យប្រវត្តិ អាចរក្សាតំណែងជាសមាជិកក្រុមប្រឹក្សាភិបាលតែក្នុងរយៈពេ
ពេញ ការងារតែប៉ុណ្ណោះ ។
អាណត្តិរបស់ក្រុមប្រឹក្សាភិបាលផ្សេងទៀត មានរយៈពេល ៣ឆ្នាំ ។ អាណត្តិនេះអាច
ទៀតបាន ។

**១១.២**-សមាជិកក្រុមប្រឹក្សាភិបាល លើកលែងតែសមាជិកដែលតំណាងនិយោជិត មិនមែន
បុគ្គលិក សហគ្រាសទេដូចនេះមិនអាចបើកប្រាក់បៀវត្សបានទេ ។ តាមសំណើរបស់
ប្រឹក្សាភិបាល រដ្ឋមន្ត្រីអាណាព្យាបាលបច្ចេកទេស និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជ
សំរេចរួមជាគោលការណ៍ចំពោះលាភការសំរាប់មុខងារជាសមាជិកក្រុមប្រឹក្សាភិបាល
កំណត់ទឹកប្រាក់នៃប្រាក់លាភការដែលត្រូវផ្តល់ជូន ។ ការបើកលាភការអាចត្រូវផ្អាក
អាជ្ញាធរ ដែលសមាជិកក្រុមប្រឹក្សាភិបាលនោះជាអ្នក តំណាងឱ្យ ចំពោះគ្រប់សមាជិក
ដែលពុំបានគោរពនូវកាតព្វកិច្ចក្នុងអាណត្តិរបស់ខ្លួន :

(I) ឧស្សាហ៍ព្យាយាម

(II) គោរពបទបញ្ញត្តិច្បាប់ បទបញ្ជា និងលក្ខន្តិកៈរបស់សហគ្រាស

(III) ការពារនយោបាយនិងផលប្រយោជន៍របស់អាជ្ញាធរ ដែលជាអ្នកចាត់តាំងអាណត្តិ ឱ្យ

(IV) កាតព្វកិច្ចរាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន ។

**មាត្រា១២.** ប្រធានអគ្គនាយកជាអ្នកតំណាងស្របច្បាប់របស់សហគ្រាស ក្នុងការធ្វើទំនាក់ទំនងជា
តតីយជន ។ ក្នុងករណីដែលការដឹកនាំ ត្រូវបានប្រគល់ឱ្យអគ្គនាយក គឺអគ្គនាយ
ហើយដែលជាតំណាងស្របច្បាប់របស់សហគ្រាស ក្នុងការធ្វើទំនាក់ទំនងជាមួយតតីយជ

**មាត្រា១៣.** ក្នុងរយៈពេល ១៥ ថ្ងៃ បន្ទាប់ពីកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល ប្រធានអគ្គនាយក ឬ
នាយក ត្រូវផ្ញើជូនរដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្ចេកទេស និងរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្
ហិរញ្ញវត្ថុ នូវតំរោងថវិកា និងគំនូសបំព្រួញហិរញ្ញប្បទាន ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្
ហិរញ្ញវត្ថុ បន្ទាប់ពីបានទទួលឯកសារក្នុងរយៈពេល១ខែ ត្រូវរៀបចំផ្តល់យោបល់រប
ជូនរដ្ឋមន្ត្រីក្រសួង អាណាព្យាបាលបច្ចេកទេស។ រដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្
ក្នុងរយៈពេល២ខែ ចាប់ពី ថ្ងៃទទួលឯកសារពីប្រធានអគ្គនាយក ឬអគ្គនាយកត្រូវបញ្

យល់ព្រមឬជំទាស់លើឯកសារទាំងនេះ ។ លិខិតយល់ព្រម ត្រូវចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្ចេកទេស ឬ តំណាងហើយត្រូវផ្ញើទៅជូនប្រធានអគ្គនាយក ឬអគ្គនាយកព្រមទាំងចំលងជូនរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ ប្រធានអគ្គនាយក ឬនាយកត្រូវជូន ពត៌មានពីបញ្ហានេះទៅក្រុមប្រឹក្សាភិបាលឱ្យបានទាន់ពេលវេលានិងដាក់អនុវត្តគំរោងថវិកា។ ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្ចេក ទេស មិនបានឆ្លើយតបតាមពេលកំណត់ទេនោះ គំរោងថវិកានេះត្រូវចាត់ទុកថាត្រូវបានយល់ព្រមហើយ ប្រធានអគ្គនាយក ឬអគ្គនាយក យកគំរោងថវិកានេះទៅអនុវត្ត ។ ប្រសិនបើក្រសួងអាណាព្យាបាលបច្ចេកទេស មានការជំទាស់លើគំរោងថវិកា ប្រធានក្រុមប្រឹក្សាភិបាលត្រូវរៀប [illegible] ទាស់នោះ ។ គំរោងថវិការបស់សហគ្រាស នឹងមិនអាចដាក់អនុវត្តបាន ដរាបណាមានការជំទាស់ពីរដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្ចេកទេស ។

មាត្រា១៤- រដ្ឋមន្ត្រីអាណាព្យាបាលបច្ចេកទេស អាចបង្ហាញការជំទាស់របស់ខ្លួនលើឯកសារដែលត្រូវបានផ្ញើមកជូនដូចមានចែងក្នុងមាត្រា១៦ នៃព្រះរាជក្រមគឺ : (I) កំណត់ហេតុនៃការប្រជុំនានារបស់ក្រុមប្រឹក្សាភិបាល(II)តារាងហិរញ្ញវត្ថុនិងរបាយការណ៍សកម្មភាព (III) របាយការណ៍នៃការផ្ទៀងផ្ទាត់គណនី ។ រដ្ឋមន្ត្រីអាណាព្យាបាលបច្ចេកទេសរៀបចំធ្វើការជំទាស់ក្នុងអំឡុងពេល ១ខែ រាប់ពីថ្ងៃ ទទួលឯកសារមក ។ក្នុងករណីដែលរដ្ឋមន្ត្រីអាណាព្យាបាលបច្ចេកទេស មិនបានឆ្លើយតប តាមពេល វេលាកំណត់ដែលបាន ផ្ញើមកជូនដោយក្រុមប្រឹក្សាភិបាល ត្រូវចាត់ទុកថាពុំមានការជំទាស់ ហើយ សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាលអាចដាក់អនុវត្តបាន ។

ប្រសិនបើរដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្ចេកទេសបង្ហាញការជំទាស់ ក្រុមប្រឹក្សាភិបាល ត្រូវរៀបចំធ្វើការពិភាក្សាជាបន្ទាន់ ដើម្បីរិះរកមធ្យោបាយដោះស្រាយការជំទាស់ទាំងនោះ ។ ក្នុងករណីដែលក្រុមប្រឹក្សាភិបាលសំរេច ពុំយកជាការនូវការជំទាស់នោះ ត្រូវមានមូលហេតុ ហើយត្រូវជូនដំណឹងពីការសំរេចនេះ ជាលាយល័ក្ខអក្សរដល់ រដ្ឋមន្ត្រីអាណាព្យាបាល ។ សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាលនេះអាចដាក់អនុវត្តបន្ទាន់ ។

មាត្រា ១៥-

១៥-១- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងនាមជាតំណាងរបស់រដ្ឋមានបេសកកម្មពីរគឺធ្វើការតាមដាន និងការត្រួតពិនិត្យលើសហគ្រាសសាធារណៈ ។ បេសកកម្មនេះ ត្រូវប្រគល់

ទៅឱ្យមន្ត្រីរាជការមួយរូប ដែលមានឈ្មោះថាមន្ត្រីត្រួតពិនិត្យរដ្ឋដូចមានចែងក្នុង មាត្រ
នៃក្រម ។

**១៥-២-** មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវបានតែងតាំង និងត្រូវដកចេញពីដំណែងវិញដោយអនុក្រឹត្យ
សំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវបានជ្រើ
ក្នុងចំណោមមន្ត្រីជាន់ខ្ពស់របស់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលបាននិងកំពុងបំពេ
ងារសាធារណៈយ៉ាងតិច៥ឆ្នាំ ។

**១៥-៣-** មន្ត្រីត្រួតពិនិត្យរដ្ឋ បំពេញមុខងាររបស់ខ្លួននៅក្រោមបញ្ជានិងការណែនាំរបស់
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុហើយត្រូវរាយការណ៍ជាទៀងទាត់ ពីកិច្ចការដែលបានអ
ដូចនេះមន្ត្រីត្រួតពិនិត្យរដ្ឋត្រូវផ្តល់ជូនរដ្ឋមន្ត្រីក្នុងមួយត្រីមាសម្តងនូវរបាយការណ៍បំពេ
ដំណើរ ការនិងលទ្ធផលនៃសហគ្រាសដែលខ្លួនពិនិត្យ ។ សេចក្តីចំលងរបាយការណ៍មួយ
អាចផ្ញើទៅជូនរដ្ឋមន្ត្រីអាណាព្យាបាលបច្ចេកទេស ប្រសិនបើរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច
ហិរញ្ញវត្ថុយល់ថាជាការចាំបាច់ ។ តាមរយៈរបាយការណ៍នេះមន្ត្រីត្រួតពិនិត្យរដ្ឋត្រ
ពត៌មានជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសុំការណែនាំនូវរាល់ បេសកក
ពិនិត្យរបស់ខ្លួន ។

**១៥-៤-** ដើម្បីបំពេញបេសកកម្មរបស់ខ្លួន មន្ត្រីត្រួតពិនិត្យរដ្ឋអាចស្នើសុំពត៌មានឬធ្វើការស្វែ
នៅនឹងកន្លែងលើគ្រប់ឯកសារ( កិច្ចសន្យាអនុសញ្ញាកំណត់សំណេរដែក្នុងរបាយការណ៍
និង បញ្ជី គណនេយ្យ ហើយត្រូវរក្សាការសំងាត់របស់សហគ្រាស ។

**១៥-៥-** មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវបានទទួលលាភការក្នុងល័ក្ខខ័ណ្ឌដូចក្នុងមាត្រា១១-២
សំរាប់សមាជិក ក្រុមប្រឹក្សាភិបាល ។

**មាត្រា ១៦-**

**១៦-១-** មន្ត្រីត្រួតពិនិត្យរដ្ឋទទួលបន្ទុកតាមដានជាប្រចាំនូវការប្រព្រឹត្តិទៅរបស់សហគ្រាស និ
ពត៌មានជូនអាជ្ញាធរព្យាបាល ជាពិសេសលើស្ថានភាពហិរញ្ញវត្ថុ ។

**១៦-២-** បេសកកម្មតាមដានរបស់មន្ត្រីត្រួតពិនិត្យរដ្ឋជាក់ស្តែង មានការតាមដានជាប្រ
សកម្មភាពរបស់សហគ្រាស និងការចូលរួមយ៉ាងសកម្មនិងសា្វពញ្ញក្នុងការងាររបស់អ
គ្រប់គ្រងរបស់សហគ្រាស ។

មន្ត្រីត្រួតពិនិត្យរដ្ឋមានសិទ្ធិចូលរួមនៅក្នុងការប្រជុំរបស់ក្រុមប្រឹក្សាភិបាល ។ មន្ត្រី
ពិនិត្យរដ្ឋត្រូវបានកោះអញ្ជើញ និងត្រូវបានផ្តល់ឯកសារដែលនឹងត្រូវពិនិត្យដោយ

ប្រឹក្សាភិបាលក្នុងឋានៈដូចសមាជិកក្រុមប្រឹក្សាភិបាលដែរ ។ មន្ត្រីត្រួតពិនិត្យរដ្ឋអាចមានយោបល់ លើបញ្ហាដែលមានចុះក្នុងរបៀបវារៈ ប៉ុន្តែពុំអាចចូលរួមក្នុងការបោះឆ្នោតទេ ជាពិសេស ត្រូវផ្តល់មតិរបស់ខ្លួនជូនក្រុមប្រឹក្សាភិបាលក្នុងការធ្វើគំរោងថវិកា និងគណនីប្រចាំឆ្នាំ ។

មន្ត្រីត្រួតពិនិត្យរដ្ឋ ត្រូវបានអញ្ជើញចូលរួមក្នុងមហាសន្និបាតហើយអាចឡើងមានមតិនិងផ្តល់យោបល់លើបញ្ហាដែលមានក្នុងរបៀបវារៈ ។

១៦-៣-មន្ត្រីត្រួតពិនិត្យរដ្ឋ ត្រូវទំនាក់ទំនងការងារយ៉ាងជិតស្និទ្ធជាមួយនឹងអគ្គនាយកដ្ឋាន និងក្រុមប្រឹក្សាភិបាលហើយត្រូវចូលរួមផ្តល់យោបល់ និងជួយសហគ្រាសក្នុងករណីចាំបាច់លើបញ្ហាដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន ។

មាត្រា ១៧-

១៧-១-មន្ត្រីត្រួតពិនិត្យរដ្ឋ ទទួលបន្ទុកត្រួតពិនិត្យប្រក្រតីនីតិភាពនៃសេចក្តីសំរេច របស់ក្រុមប្រឹក្សា ភិបាលហើយមានអំណាចធ្វើការជំទាស់ដល់ការប្រតិបត្តិនៃសេចក្តីសំរេចនោះ ។

អំណាចធ្វើការជំទាស់របស់មន្ត្រីត្រួតពិនិត្យរដ្ឋ ពុំប៉ះពាល់ទៅលើកិច្ចគ្រប់គ្រងរបស់ប្រធានអគ្គនាយកឬអគ្គនាយកទេ ។ អំណាចជំទាស់របស់មន្ត្រីត្រួតពិនិត្យរដ្ឋអាចធ្វើភ្លាម១ក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាលឬយ៉ាងយូរក្នុងអំឡុងពាថ្ងៃបន្ទាប់ពីការប្រជុំរបស់ក្រុមប្រឹក្សាភិបាល ។ អំណាចជំទាស់មានលក្ខណៈជាការត្រួតពិនិត្យប្រក្រតីនីតិភាព គឺពុំមែនត្រួតពិនិត្យកាលានុវត្តភាពនៃសេចក្តីសំរេចចិត្តទេ ។

១- កម្មវត្ថុរបស់សហគ្រាស

២- ការតព្វកិច្ចរបស់សហគ្រាសលើការអនុវត្តបទបញ្ញត្តិនិងបទបញ្ជាជាធរមាន លក្ខន្តិកៈរបស់សហគ្រាស ឬសេចក្តីសំរេចរបស់រដ្ឋាភិបាល ។

៣- សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ដែលមានពីមុនមក ។

១៧-២-ការជំទាស់របស់មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវជូនដំណឹងទៅក្រុមប្រឹក្សាភិបាលតាមរបៀបពីរយ៉ាងៈ -

- ដោយផ្ទាល់មាត់ក្នុងពេលប្រជុំ : ក្នុងករណីនេះ ការជំទាស់ត្រូវកត់ត្រាក្នុងកំណត់ហេតុនៃអង្គប្រជុំ ។

ឬក្នុងរយៈពេលពាថ្ងៃ ធ្វើការក្រោយប្រជុំ : ក្នុងករណីនេះ ការជំទាស់ត្រូវតែធ្វើឡើងជាលាយលក្ខអក្សរ ហើយផ្ញើជូនប្រធានក្រុមប្រឹក្សាភិបាល ។

**១៧.៣.**ការជំទាស់នេះត្រូវមានការយល់ស្របពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬរដ្ឋមន្ត្រីអ
ព្យាបាលបច្ចេកទេស ក្នុងរយៈពេល៤ថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃសំដែងចេញនូវការជំទាស់ ។
លើសពីរយៈពេលកំណត់ ប្រសិនបើពុំមានការបញ្ជាក់បន្ថែមនេះទេ ការសំរេចរបស់
ប្រឹក្សាភិបាលនឹងត្រូវអនុវត្តជាបន្ទាន់ ។

ប្រសិនបើរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬរដ្ឋមន្ត្រីអាណាព្យាបាលបច្ចេកទេស
ស្របលើការជំទាស់ដោយលិខិតបដិសេធ ឬដោយធ្វើការកែសំរួលសេចក្តីសំរេចចិត្តពា
នោះ សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាលពុំអាចអនុវត្តបានឡើយ ។ ក្នុងករណីនេះ ប្រ
ក្រុមប្រឹក្សាភិបាលត្រូវរៀបចំប្រជុំក្រុមប្រឹក្សាភិបាលឱ្យបានឆាប់បំផុតដើម្បីធ្វើការសំរេច
ក្រុមប្រឹក្សាភិបាលអាចបដិសេធនូវសេចក្តីសំរេចរបស់ខ្លួន ឬមួយធ្វើការកែសំរួលតាមសំ
ពរអាជ្ញាធរអាណាព្យាបាល ។ ក្នុងករណីទីពីរក្រោយនេះ សេចក្តីសំរេចអាចអនុវត្តជាប
បាន ។

**មាត្រា ១៨.** គណនីប្រចាំឆ្នាំរបស់សហគ្រាសសាធារណៈ ត្រូវជាកម្មវត្ថុនៃការផ្ទៀងផ្ទាត់ និងការ ប
របស់ស្នងការគណនី ។

ស្នងការគណនីត្រូវបានជ្រើសរើសដោយក្រុមប្រឹក្សាភិបាលដែលជាអ្នកកំណត់លាភការផ
ត្រូវផ្តល់ជូនស្នងការគណនីនេះផងដែរ ។ ការជ្រើសរើសនេះត្រូវធ្វើលើបញ្ជីនៃរូបវន្តបុគ្គ
នីតិបុគ្គលដែលមានសញ្ជាតិកម្ពុជា និងមានការយល់ព្រមដោយប្រកាសរបស់រដ្ឋមន្ត្រីក្រ
សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ការតែងតាំងស្នងការគណនី ធ្វើឡើងតាមសេចក្តីសំរេចរបស់រដ្ឋមន្ត្រីក្រសួងសេ
និងហិរញ្ញវត្ថុ ក្នុងអាណត្តិដែលអាចបន្តជាថ្មីបន្ថែមលើពាការិយបរិច្ឆេទនៃសហគ្រាស ។

ស្នងការគណនីបំពេញបេសកកម្មទៅតាមបែបផែន
ដែលកំណត់ដោយអនុក្រឹត្យតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១៩.**

**១៩.១.**ភាគកម្មរបស់រដ្ឋដែលរួមមាន **គ.ស.ស ក្រ.រ** និងភាគកម្ម **ក្រ.ច** ត្រូវគ្រប់
ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអាណាព្យាបាលបច្ចេកទេស ។

ភាគកម្មរបស់ **គ.ស.ស.ក្រ.រ** និងរបស់ **ក្រ.ច** ដែលភាគកម្មសាធារណៈជាចំនួ
ច្រើននៅក្នុងដើមទុនរបស់ **ក្រ.ច** ត្រូវគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាលរបស់អង្គភា

នេះ ។ មុនពេលសំរេចធ្វើការទិញភាគកម្មក្នុងក្រុមហ៊ុនចំរុះ ក្រុមប្រឹក្សាភិបាលទាំងនេះ ត្រូវស្នើសុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងអាណាព្យាបាលបច្ចេកទេស ។

**១៩_២_**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចាត់ចែងភាគកម្មផ្ទាល់របស់រដ្ឋក្នុងល័ក្ខខ័ណ្ឌដូចតទៅ :

១- វាយតំលៃកាលានុវត្តភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃការបង្កើត **គ,ស,ស** និង **គ្រ,ស** ធ្វើភាគកម្មក្នុង **គ្រ,ច**

២-អនុវត្តឱ្យបានសំរេចនូវប្រតិបត្តិការប្រមូលភាគទុនជាសាច់ប្រាក់ ឬជាវត្ថុ ឬការធ្វើលទ្ធកម្មភាគហ៊ុនដោយអនុលោមតាមទិសដៅដែលបានសំរេចដោយរាជរដ្ឋាភិបាល និងតាមបទបញ្ញត្តិនៃច្បាប់ និងបទបញ្ជានានាស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋ ។

៣- កាន់កាប់រក្សាទុកនូវមូលប័ត្រដែលតំណាងភាគកម្មសរុបរបស់រដ្ឋ ។

៤- ភ្ជាប់ឱ្យបានជាប្រចាំនូវពត៌មានចាំបាច់សំរាប់ធ្វើការតាមដានលើដំណើរការ និងលើការផ្តល់ផលរបស់សហគ្រាសសាធារណៈ

៥- ចូលរួមជាមួយក្រសួងអាណាព្យាបាលបច្ចេកទេសក្នុងការរៀបចំផែនការធ្វើនីតិសម្បទា និងរៀបចំរចនាសម្ព័ន្ធសហគ្រាសសាធារណៈឡើងវិញ
ហើយត្រូវធ្វើការតាមដានលើការ អនុវត្ត

៦- ចូលរួមជាមួយក្រសួងអាណាព្យាបាលបច្ចេកទេស ក្នុងការដាក់តែងនូវគោលនយោបាយសំរាប់ទំនាក់ទំនងលើកិច្ចសន្យារវាងរដ្ឋជាមួយសហគ្រាសសាធារណៈ
ហើយត្រូវធ្វើការតាម ដានការអនុវត្តន៍ ។

**មាត្រា ២០_**ប្រធានអគ្គនាយក ឬអគ្គនាយកនៃ **គ,ស,ស គ្រ,ស** ឬ **គ្រ,ច** ដែលមានភាគកម្មសាធារណៈជាចំនួនភាគច្រើន ត្រូវមានសញ្ជាតិខ្មែរ និងត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួងអាណាព្យាបាលបច្ចេកទេស ដោយឈរជាពិសេសលើលក្ខណៈវិនិច្ឆ័យនៃសមត្ថភាពនិងការពិសោធន៍ ។

**មាត្រា ២១_**-គ្រប់ការរំលាយបញ្ចូលគ្នា ការបំបែក ឬការជំរះបញ្ជីនៃ **គ,ស,ស** ឬ **គ្រ,ស** ត្រូវធ្វើឡើងដោយអនុក្រឹត្យ តាមសំណើរួមរបស់រដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្ចេកទេស និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រោយមានការ ផ្តល់យោបល់ពីក្រុមប្រឹក្សាភិបាលរបស់សហគ្រាសពាក់ព័ន្ធ ។

-គ្រប់ការរំលាយបញ្ចូលគ្នា ការបំបែក ឬការជំរះបញ្ជីនៃ **គ្រ,ច** ដែលមានភាគកម្មសាធារណៈជាចំនួនភាគច្រើនត្រូវធ្វើឡើងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិង

ក្រោយមានការផ្តល់យោបល់ពីរដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្ចេកទេស និងពីក្រុម
ភិបាលរបស់សហគ្រាសពាក់ព័ន្ធ ។

-គ្រប់ការរំលាយបញ្ចូលគ្នា ការបំបែក ឬការជំរះបញ្ជីនៃ គ្រ.ច ដែលមានភា
សាធារណៈ ជាចំនួនភាគហ៊ុនតិច ត្រូវធ្វើឡើងតាមទំរង់បែបបទដែលមានកំណត់ក្នុងល
របស់ក្រុមហ៊ុន ។

**មាត្រា ២២-**

**២២-១-**អនុប្បទាននៃ **គ,ស,ស** ឬការលក់ភាគហ៊ុនរបស់ **គ្រ.រ** ត្រូវមានការអនុញ្ញាត
អនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្ចេកទេស និងរដ្ឋមន្ត្រី
សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រោយមានការផ្តល់យោបល់ពីក្រុមប្រឹក្សាភិបាលរបស់សហ
ពាក់ព័ន្ធ ។

**២២-២-**អនុប្បទាននៃភាគហ៊ុនរបស់រដ្ឋក្នុង **គ្រ.ច** ដែលមានភាគកម្មសាធារណៈ ជាចំនួ
ច្រើនត្រូវមានការអនុញ្ញាតដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រោយ
ការផ្តល់យោបល់ពីរដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្ចេកទេស និងក្រុមប្រឹក្សាភិបាល
សហគ្រាសពាក់ ព័ន្ធ ។

អនុប្បទាននៃភាគហ៊ុនរបស់ **គ,ស,ស** ឬ **គ្រ.រ** នៅក្នុង **គ្រ.ច** ណាមួយ
មានភាគកម្មភាពសាធារណៈជាចំនួនភាគច្រើន ត្រូវមានការយល់ព្រមពីក្រសួងអ
ព្យាបាលបច្ចេក ទេសនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមសំណើរបស់ក្រុមប្រឹក្សាភិ
ដែលជាតំណាង ម្ចាស់ភាគហ៊ុន ។

**២២-៣-**អនុប្បទាននៃភាគហ៊ុនរបស់រដ្ឋនៅក្នុង**គ្រ.ច**ដែលមានភាគកម្មសាធារណៈជាចំនួនភាគ
ត្រូវសំរេចឡើងតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានកា
យោបល់ពីរដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្ចេកទេស ។

អនុប្បទាននៃភាគហ៊ុនរបស់ **គ,ស,ស** ឬ**គ្រ.រ** នៅក្នុង **គ្រ.ច** ដែលមានភា
សាធារណៈជាចំនួនភាគតិចត្រូវមានការយល់ព្រមពីក្រសួងអាណាព្យាបាលបច្ចេកទេស
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ដែលជាតំណាង
ភាគហ៊ុន ។

**មាត្រា ៣១.-**

**៣១.១-** មូលធនរបស់ក្រុមហ៊ុន អាចបែងចែកជាភាគទុនជារូបិយវត្ថុ និងភាគទុនជាចលនៈ និងអចលនៈទ្រព្យ ។

ភាគទុនជាចលនៈ និងអចលនៈទ្រព្យត្រូវបានវាយតំលៃដោយគណៈកម្មការវាយតំលៃមួយរួមមានសមាជិកចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងអាណាព្យាបាល បច្ចេកទេស និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**៣១.២-** មូលធនរបស់ក្រុមហ៊ុនត្រូវបែងចែកជាភាគហ៊ុនដែលមានចុះឈ្មោះម្ចាស់ភាគហ៊ុន ហើយត្រូវចុះបញ្ជីទាំងស្រុងនៅពេលបង្កើត **គ្រ,ន** ។

ភាគហ៊ុនត្រូវបានបង់ចូលក្នុងល័ក្ខខ័ណ្ឌដែល បានកំណត់ដោយនីតិក្រុមហ៊ុនពាណិជ្ជកម្មលើកលែងតែមានបទបញ្ញត្តិដោយឡែកដែល ចែងក្នុងអនុក្រឹត្យស្តីពីការបង្កើត **គ្រ,ន** ។

ការបង់ចូលនូវភាគហ៊ុនជារូបិយវត្ថុ ត្រូវបានទទួលដោយប័ណ្ណចំណូលមួយរៀបចំដោយអាណត្តិគាហកៈរបស់រដ្ឋមន្ត្រីក្រសួងអាណាព្យា បាលបច្ចេកទេស ។ អាណត្តិគាហកៈត្រូវយកមូលនិធិទៅតំកល់ទុកក្នុងគណនីមួយនៅរតនាគារជាតិឬនៅធនាគារជាតិនៃកម្ពុជា ។ ទុនទាំងនេះមិនអាចប្រើមុនពេលចុះបញ្ជីក្រុមហ៊ុននៅ ក្នុងបញ្ជីពាណិជ្ជកម្មបានឡើយ ។

ការបង់ចូលនូវភាគហ៊ុនជាចលនៈ និង អចលនៈទ្រព្យ ត្រូវមានធ្វើបញ្ជីសារពើភ័ណ្ឌដែលចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួង អាណាព្យាបាលបច្ចេកទេស និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយត្រូវភ្ជាប់ជា ឧបសម្ព័ន្ធជាមួយលក្ខន្តិកៈ **គ្រ,ន** ។

**មាត្រា ៣២.-** ប្រតិបត្តិការហិរញ្ញវត្ថុទាំងឡាយរបស់រដ្ឋ ក្នុងឋានៈជាម្ចាស់ភាគហ៊ុនជាមួយ **គ្រ,ន** ត្រូវតែអនុលោមតាមបទបញ្ញត្តិដែលចែងដោយព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីប្រព័ន្ធច្បាប់ហិរញ្ញវត្ថុ និងលិខិតបទដ្ឋានបន្តបន្ទាប់ក្រោយៗទៀត ។ កិច្ចការ នេះតំរូវ :

- ភាគទុនជាមូលធនចាប់ពីពេលបង្កើត **គ្រ,ន** ឬក្រោយការបង្កើតត្រូវបានគ្រោង និងអនុញ្ញាត ដោយច្បាប់ហិរញ្ញវត្ថុដោយចាត់ទុកចំណាយលើការវិនិយោគរបស់រដ្ឋក្នុងកិច្ចជាប្រតិបត្តិការ ហិរញ្ញវត្ថុ
- ចំណូលដែលរដ្ឋបានមកពី **គ្រ,ន** គឺជាប្រភពចំណូលថវិកា :

(I)-ទុកជាចំណូលមូលធនក្នុងប្រទេស ក្នុងករណីលក់ចំណែកភាគហ៊ុន

(II)-ឬទុកជាចំណូលនៃទ្រព្យសម្បត្តិរដ្ឋក្នុងករណីជាប្រាក់ចំណេញតាមភាគហ៊ុន ។

## ជំពូកទី ៣

## ភាគកម្មសាធារណៈក្នុងមូលធនក្រុមហ៊ុនចំរុះ

**មាត្រា ៣៣.** មានតែរដ្ឋ គ,ស,ស ក្រ,រ និងនីតិបុគ្គលសាធារណៈប៉ុណ្ណោះដែលមានសិទ្ធិកាន់កាប់ភាគកម្ម សាធារណៈ ។

អាជ្ញាធរមូលដ្ឋានក្នុងលក្ខណៈដែលពុំមាននីតិបុគ្គលភាពមិនមានសិទ្ធិកាន់ កាប់ភាគកម្មនៃដើមទុនក្រុមហ៊ុនណាមួយបានទេ ។

ភាគកម្មជាចំនួនភាគច្រើនដែលបាន ដាក់ក្នុងសាខា ដោយក្រុមហ៊ុនមួយដែលមានភាគកម្មសាធារណៈជាចំនួនភាគច្រើនមិនអនុញ្ញាតឱ្យសាខា
នេះមានលក្ខន្តិកៈជាសហគ្រាសសធារណៈទេ ។

**មាត្រា ៣៤.**

៣៤.១. សកម្មភាពរបស់ ក្រ,រ ដែលធ្វើឡើងដើម្បីសំរេចគោលដៅរបស់ក្រុមហ៊ុន ត្រូវស្ថិតនៅក្រោមនីតិឯកជនលើកលែងតែមានបដិប្បញ្ញត្តិនៃច្បាប់ និងបទបញ្ជា ។

៣៤.២. ក្រុមហ៊ុនចំរុះទាំងឡាយដែល ក្នុងនោះភាគកម្មសាធារណៈស្មើឬលើសពី៥១ភាគរយ នៃដើមទុនរបស់ក្រុមហ៊ុន ឬសិទ្ធិបោះឆ្នោតគឺមានលក្ខណៈជាសហគ្រាសសាធារណៈ ។ ក្នុងលក្ខណៈនេះក្រុមហ៊ុនចំរុះ ត្រូវតែអនុវត្តបទបញ្ញត្តិទាំងឡាយដូចមានចែងនៅក្នុងជំពូកទី១ និង ជំពូកទី២នៃ ព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ។

**មាត្រា ៣៥.**

៣៥.១. ភាគទុនរបស់រដ្ឋក្នុង គ,ស,ស ក្រ,រ ឬរបស់នីតិបុគ្គលសាធារណៈក្នុងដើមទុនរបស់ ក្រ,ច អាចជាភាគទុនជារូបិយវត្ថុ និងជាភាគជាទុនចលនៈ និងអចលនៈទ្រព្យ ។

៣៥.២. ការបង់ចូលនូវភាគហ៊ុនជារូបិយវត្ថុ ក្នុងមូលធន ក្រ,ច ដែលមានភាគកម្មសាធារណៈជាចំនួនភាគច្រើន ត្រូវបានទទួលដោយប័ណ្ណចំណូលដែលចុះហត្ថលេខាដោយ (I) អាណត្តិគាហកៈចាត់ តាំងដោយរដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្ចេកទេសចំពោះភាគទុនរបស់រដ្ឋ (II) ម្ចាស់ភាគហ៊ុន ផ្សេងទៀតចំពោះភាគទុនរបស់ខ្លួនគេ ។ អាណត្តិគាហកៈរបស់រដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្ចេកទេសចាត់តាំងធ្វើយ៉ាងណាឱ្យមូលនិធិសរុប ទាំងអស់ត្រូវបានយកទៅតំកល់ទុកក្នុងគណនីមួយនៅ រតនាគារជាតិ ឬធនាគារជាតិនៃកម្ពុជា ។ ទុនទាំងនេះមិនអាចប្រើមុនពេលចុះឈ្មោះក្រុមហ៊ុនក្នុង បញ្ជីពាណិជ្ជកម្មបានឡើយ ។ ការបង់ចូលនៅភាគហ៊ុនជារូបិយវត្ថុក្នុងមូលធន ក្រ,ច ដែលមានភាគកម្មសាធារណៈជាចំនួនភាគតិច

ត្រូវបានទទួលដោយប័ណ្ណចំណូលដែលចុះហត្ថលេខាដោយម្ចាស់ភាគហ៊ុនម្នាក់ៗចំពោះភាគទុនរបស់ខ្លួនគេ ។ ស្ថាបនិកដែលចាត់តាំងដោយមានការឯកភាពពីម្ចាស់ភាគហ៊ុន សំរាប់ធានាទំរង់បែបបទនៃការបង្កើត ត្រ,ច ត្រូវចាត់ចែងធ្វើយ៉ាងណាឱ្យមូលនិធិសរុបទាំងអស់ត្រូវបានយកទៅតំកល់ទុកក្នុងគណនីមួយនៅធនាគារជាតិ ឬធនាគារជាតិនៃកម្ពុជា ។ ទុនទាំងនេះ មិនអាចប្រើមុន ពេលចុះបញ្ជីក្រុមហ៊ុនក្នុងបញ្ជីពាណិជ្ជកម្ម និងក្រុមហ៊ុនបានឡើយ ។

**៣៥.៣**-ភាគទុនជាទ្រព្យសម្បត្តិរបស់រដ្ឋ **គ,ស,ស** **ត្រ,ទ** ឬរបស់នីតិបុគ្គលសាធារណៈត្រូវបានវាយតំលៃដោយគណៈកម្មការវាយតំលៃមួយ ចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្ចេកទេស និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ការបង់ចូលនូវភាគហ៊ុនជាចលនៈ និងអចលនៈទ្រព្យ ត្រូវមានធ្វើបញ្ជីសារពើភ័ណ្ឌដែលចុះ ហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្ចេកទេស និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយដែលត្រូវភ្ជាប់ជាឧបសម្ព័ន្ធជាមួយលក្ខន្តិកៈ **ត្រ,ច** ។

**មាត្រា ៣៦.-**

**៣៦.១**-មូលធនរបស់ក្រុមហ៊ុន ត្រូវបែងចែកជាភាគហ៊ុនដែលមានចុះឈ្មោះម្ចាស់ភាគហ៊ុនហើយត្រូវចុះបញ្ជីទាំងស្រុងនៅពេលបង្កើត **ត្រ,ច** ។

ភាគហ៊ុនត្រូវបានបង់ចូលក្នុងល័ក្ខខណ្ឌ ដែលបានកំណត់ដោយលក្ខន្តិកៈរបស់ **ត្រ,ច** ។

**៣៦.២**-ភាគហ៊ុនដែលកាន់កាប់ដោយរដ្ឋ **គ,ស,ស** **ត្រ,ទ** ឬនីតិបុគ្គលសាធារណៈ និងដោយម្ចាស់ភាគហ៊ុនម្នាក់ឬច្រើននាក់នៃ **ត្រ,ច** ត្រូវរៀបជាពីរប្រភេទផ្សេងគ្នាតាមលក្ខន្តិកៈរបស់ក្រុមហ៊ុន ។

ឯកសិទ្ធិរាប់បញ្ចូលទាំងឯកសិទ្ធិស្របច្បាប់ ដែលមានចែងក្នុងច្បាប់ដែល ត្រូវបានផ្ដល់ឱ្យប្រភេទភាគហ៊ុនណាមួយក្នុងចំណោមប្រភេទទាំងពីរ ចាំបាច់ត្រូវមានព្រោងទុកក្នុងអនុសញ្ញានៃ ម្ចាស់ភាគហ៊ុនដែលចុះហត្ថលេខាដោយភាគីនានានៅមុនការ បង្កើត **ត្រ,ច** ។

**មាត្រា ៣៧.-**

**៣៧.១**-លក្ខន្តិកៈ **ត្រ,ច** ដែលមានភាគកម្មសាធារណៈជាចំនួនភាគច្រើន ត្រូវបានរៀបចំឡើងដោយអនុលោមជាពិសេសតាមបទបញ្ញត្តិមាត្រា ៣៤-២ ខាងលើ ដោយរដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្ចេកទេសដោយសហការជាមួយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**៣៧.២**-លក្ខន្តិកៈ **ត្រ,ច** ដែលមានភាគកម្មសាធារណៈជាចំនួនភាគតិច ត្រូវបានរៀបចំឡើងដោយអនុលោមជាពិសេសតាមបទបញ្ញត្តិមាត្រា៣៤-២ខាងលើដោយម្ចាស់ភាគហ៊ុនឯកជន

ម្នាក់ឬច្រើននាក់ដោយសហការជាមួយរដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្ចេកទេស និងរដ្ឋ
ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៣៨.-**

**៣៨.១-** ទំរង់នៃការបង្កើត **ក្រ,ច** ដែលមានភាគកម្មសាធារណៈជាចំនួនភាគច្រើន ត្រូវធ្វើ
ដោយអនុលោមទៅតាមវិធានដែលមានចែងក្នុងបទបញ្ញត្តិស្តីពីក្រុមហ៊ុនពាណិជ្ជកម្ម ដ
អាណត្តិគាហកៈ ដែលចាត់តាំងឡើងដោយរដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្ចេកទេស រ
ដែលជាអ្នក :

១- ដាក់លក្ខន្តិកៈជូនរដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្ចេកទេស និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច
ហិរញ្ញវត្ថុ ចុះហត្ថលេខារួមក្នុងនាមរដ្ឋ ។

២- ចុះឈ្មោះក្រុមហ៊ុនក្នុងបញ្ជីពាណិជ្ជកម្ម ហើយជារួមគឺបំពេញបែបបទចាំបាច់ ផ្សេងៗ
នីតិក្រុម ហ៊ុនពាណិជ្ជកម្ម ។

**៣៨.២-** ទំរង់នៃការបង្កើត **ក្រ,ច** ដែលមានភាគកម្មសាធារណៈជាចំនួនភាគតិច ត្រូវធ្វើ
ដោយស្ថាបនិក ដែលចាត់តាំងដោយមានការឯកភាពពីម្ចាស់ភាគហ៊ុនទាំងឡាយ អនុ
ទៅតាម វិធានដែលមានចែងក្នុងបទបញ្ញត្តិស្តីពីក្រុមហ៊ុនពាណិជ្ជកម្ម ។

**៣៨.៣- ក្រ,វ** អាចមាននីតិបុគ្គលចាប់ពីថ្ងៃចុះឈ្មោះក្រុមហ៊ុនក្នុងបញ្ជីពាណិជ្ជកម្ម ។ មុនក
ឈ្មោះក្រុមហ៊ុនក្នុងបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុននេះមិនអាចសំរេចកិច្ចការអ្វីមួយបានទេ
លែងតែ កិច្ចការដែលសំរេចដោយអាណត្តិគាហកៈ របស់រដ្ឋមន្ត្រីក្រសួងអាណាព្យា
បច្ចេកទេស ឬដោយ ស្ថាបនិកដែលត្រូវបានចាត់តាំងដោយម្ចាស់ភាគហ៊ុនទាំងឡាយ ។

**មាត្រា ៣៩.-** ប្រតិបត្តិការហិរញ្ញវត្ថុទាំងឡាយដែលរដ្ឋក្នុងឋានៈជាម្ចាស់ភាគហ៊ុនអនុវត្តជាមួយ
ត្រូវអនុលោមតាមបទបញ្ញត្តិដែលចែងដោយព្រះរាជក្រមលេខ ០១ នស/៩៣ ចុះថ្ងៃ
ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីប្រព័ន្ធច្បាប់ហិរញ្ញវត្ថុ និងលិខិតបទដ្ឋានបន្តបន្ទាប់ក្រោយៗទៀត

កិច្ច ការនេះតំរូវ :

- ភាគទុនជារូបិយវត្ថុក្នុងមូលធនចាប់ពីពេលបង្កើត **ក្រ,ច** ឬក្រោយពេលបង្កើតត្រូ
គ្រោង និងអនុញ្ញាតដោយច្បាប់ហិរញ្ញវត្ថុ ដោយចាត់ទុកជាចំណាយលើការវិនិយោគរ
ក្នុងកិច្ចជាប្រតិបត្តិការហិរញ្ញវត្ថុ
- ចំណូលដែលរដ្ឋបានមកពី **ក្រ,ច** គឺជាប្រភពចំណូលថវិកា :

(I)- ទុកជាចំណូលមូលធនក្នុងប្រទេស ក្នុងករណីមានការលក់ចំណែកភាគហ៊ុន

(II)-ឬទុកជាចំណូលនៃទ្រព្យសម្បត្តិរដ្ឋ ក្នុងករណីដែលជាប្រាក់ចំណេញតាមភាគហ៊ុន ។

## ជំពូកទី ៩

## អវសានបញ្ញត្តិ

**មាត្រា ៤០.-** បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងបទបញ្ញត្តិ ដែលមានចែងក្នុងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤១.-** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាគ្រប់ក្រសួង-ស្ថាប័ន និងអភិបាលគ្រប់ខេត្ត-ក្រុង មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពី ថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

**សូមគោរពជូន**

សម្តេចនាយករដ្ឋមន្ត្រីទី២

ហត្ថលេខា

**គាត ឈន់**

ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីតសម្ព័ន្ធទាំងអភិវឌ្ឍន៍

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

* * *

## អនុក្រឹត្យ លេខ ៤២ អនក្រ.បក

## ស្តីពី ស្ថាប័ការគណនីនៃសហគ្រាសសាធារណៈ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា